ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...០១០................សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការតព្វកិច្ចដាក់ឧបករណ៍វាស់ចំណុះ ស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា របស់សហគ្រាសផលិតក្នុងស្រុក

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអត្រាអាករពិសេសលើមុខទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ២១០ អនក្រ.បក ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញលើមុខទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអត្រាពន្ធគយ អត្រាអាករពិសេស និងអត្រាអាករនាំចេញលើមុខទំនិញមួយចំនួន
- បានឃើញប្រកាសលេខ ៣៤១ ប្រក.សហវ.ពដ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីអាករពិសេសលើទំនិញ និងសេវាមួយចំនួន
- បានឃើញប្រកាសលេខ ០១២ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ស្តីពីការកែសម្រួលការកំណត់មូលដ្ឋានគិតអាករពិសេសលើមុខទំនិញមួយចំនួនដែលផលិតក្នុងស្រុក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ប្រការ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់អំពីវិធាន និងនីតិវិធីគ្រប់គ្រងការប្រើប្រាស់ឧបករណ៍វាស់ចំណុះស្រាបៀរ និង/ឬភេសជ្ជៈគ្មានជាតិសុរា ដែលផលិតក្នុងស្រុក និងពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធអាករគ្រប់ប្រភេទ ជាពិសេសចំណូលអាករពិសេសលើស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងធានាបាននូវការប្រកួតប្រជែងដោយស្មើភាព។

## ប្រការ២.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរោងចក្រដែលជាអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ដែលប្រកបអាជីវកម្មផលិតស្រាបៀរ និង/ឬភេសជ្ជៈគ្មានជាតិសុរានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ប្រការ៣.- និយមន័យ

សម្រាប់គោលដៅនៃប្រកាសនេះ÷

១-ពាក្យ "**ស្រាបៀរ**" សំដៅដល់ភេសជ្ជៈទាំងឡាយណាដែលផ្សំឡើងពីស្រូវសាលី(ម៉ាលត៍) ផ្កាហប់ ទឹកនិងមេដំបែ ឬភេសជ្ជៈដទៃៗទៀតដែលមានឈ្មោះជាស្រាបៀរ។

២-ពាក្យ "**ភេសជ្ជៈគ្មានជាតិសុរា**" សំដៅដល់ទឹកដែលមានជាតិឧស្ម័ន ឬដាក់ស្ករ ឬដាក់សារជាតិផ្អែមផ្សេងទៀត ឬដាក់គ្រឿងក្រអូប ឬភេសជ្ជៈដទៃទៀតដែលគ្មានជាតិសុរា លើកលែងតែ ទឹកនិងទឹកមីណេរ៉ាល ទឹកដោះគោ ទឹកដមផ្លែឈើ ឬទឹកដមបន្លែ។

៣-ពាក្យ "**អ្នកផលិត**" សំដៅដល់សហគ្រាសដែលធ្វើការផលិតស្រាបៀរ និង/ឬភេសជ្ជៈគ្មានជាតិសុរា។

៤-ពាក្យ "**រោងចក្រផលិត**" សំដៅដល់ទីកន្លែងដែលស្រាបៀរ និង/ឬភេសជ្ជៈគ្មានជាតិសុរា ត្រូវបានផលិតក្នុងសកម្មភាពបំប្លែងវត្ថុធាតុដើម វេចខ្ចប់ ច្រកបំពេញឱ្យទៅជាផលិតផលពាក់កណ្តាលសម្រេច ឬផលិតផលសម្រេច។

៥-ពាក្យ "**ខ្សែច្រវាក់ផលិតកម្មវេចខ្ចប់**" សំដៅដល់ប្រព័ន្ធបង្គុំ ឧបករណ៍ គ្រឿងម៉ាស៊ីនបម្រើការដល់កិច្ចដំណើរការផលិតកម្មសម្រាប់វេចខ្ចប់ស្រាបៀរ ឬភេសជ្ជៈគ្មានជាតិសុរាចូលទៅក្នុងដប កំប៉ុង ធុង ឬការវេចខ្ចប់ក្នុងទម្រង់ផ្សេងៗទៀត។

៦-ពាក្យ "**ឧបករណ៍វាស់ចំណុះ**" សំដៅដល់នាឡិកាវាស់ចំណុះ នាឡិកាវិភាគសារធាតុរាវ និងប្រអប់ត្រួតពិនិត្យទិន្នន័យ។

៧-ពាក្យ "**នាឡិកាវាស់ចំណុះ**" (Flowmeter) សំដៅដល់ឧបករណ៍ដើរដោយចរន្តអគ្គិសនីដែលវាស់វិហ្សរបស់សារធាតុរាវសរុបដែលហូរកាត់តាមបំពង់ទុយោពីធុងស្តុកស្រាបៀរ ឬភេសជ្ជៈគ្មានជាតិសុរាច្រោះរួចទៅកាន់ខ្សែច្រវាក់ផលិតកម្មវេចខ្ចប់។

៨-ពាក្យ "**នាឡិកាវិភាគសារធាតុរាវ**" (Conductivity Meter) សំដៅដល់ឧបករណ៍ដើរដោយចរន្តអគ្គិសនីដែលអាចញែកឱ្យដឹងពីភាពខុសគ្នារវាងស្រាបៀរ ភេសជ្ជៈគ្មានជាតិសុរា និងសារធាតុរាវដទៃទៀតដែលហូរកាត់បំពង់ទុយោ ដូចជាទឹក ទឹកសាប៊ូលាងធុង ជាដើម។

៩-ពាក្យ "**ប្រអប់ត្រួតពិនិត្យទិន្នន័យ**" (Field Control Box) សំដៅដល់ប្រអប់ត្រូវបានបិទជិត ដែលផ្ទុកទិន្នន័យពីនាឡិកាវាស់ចំណុះស្រាបៀរ ឬភេសជ្ជៈគ្មានជាតិសុរា និងនាឡិកាវិភាគសារធាតុរាវ។

## ប្រការ៤.- ការតព្វកិច្ចក្នុងការដំឡើង និងការប្រើប្រាស់ឧបករណ៍វាស់ចំណុះ

១-អ្នកផលិតមានកាតព្វកិច្ចដំឡើងឧបករណ៍វាស់ចំណុះ ស្រាបៀរ និង/ឬភេសជ្ជៈគ្មានជាតិសុរា តាមចំណុចទីតាំង និងបច្ចេកទេសដំឡើង តាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ។

២-អ្នកផលិតត្រូវប្រើប្រាស់នាឡិកាវាស់ចំណុះ និងនាឡិកាវិភាគសារធាតុរាវ នៅគ្រប់ខ្សែច្រវាក់ផលិតកម្មវេចខ្ចប់នីមួយៗជាប្រចាំ។

៣-អ្នកផលិតត្រូវការពារនូវការបាត់បង់ ការខូចខាត ឬការក្លែងបន្លំទិន្នន័យ និងថែទាំឧបករណ៍វាស់ចំណុះ ព្រមទាំងធានាឱ្យមានដំណើរការប្រក្រតីជាប់ជាប្រចាំ។

៤-អ្នកផលិតត្រូវផ្ដល់ព័ត៌មានជាបន្ទាន់ជូនអគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីដែលនាឡិកាវាស់ចំណុះឬនាឡិកាវិភាគសារធាតុរាវ ឬប្រអប់ត្រួតពិនិត្យទិន្នន័យ ឬសោសុវត្ថិភាព ឬសៀលសុវត្ថិភាព និងសុក្រឹតភាពទិន្នន័យដែលពាក់ព័ន្ធទាំងអស់ មានបញ្ហាខូច បែកបាក់ ឈប់ដំណើរការ ឬបាត់ ។ល។

៥-អ្នកផលិតត្រូវស្នើសុំការឯកភាពពីអគ្គនាយកដ្ឋានពន្ធដារជាមុន មុនពេលធ្វើការផ្លាស់ប្ដូរទីតាំងដំឡើងនាឡិកាវាស់ចំណុះ ឬនាឡិកាវិភាគសារធាតុរាវ ឬប្រអប់ត្រួតពិនិត្យទិន្នន័យ។

៦-អ្នកផលិតត្រូវអនុញ្ញាតឱ្យមន្ត្រីពន្ធដារពិនិត្យឧបករណ៍វាស់ចំណុះដោយផ្ទាល់ ឬភ្ជាប់ចូលប្រព័ន្ធអេឡិចត្រូនិកគ្រប់ពេលវេលា។

៧-អ្នកផលិតត្រូវមានឧបករណ៍វាស់ចំណុះបម្រុងទុកគ្រប់គ្រាន់ ដែលមានកម្រិតលក្ខណៈស្ដង់ដារដូចគ្នា សម្រាប់ផ្លាស់ប្ដូរភ្លាមៗក្នុងពេលចាំបាច់។

៨-នាឡិកាវាស់ចំណុះ និងនាឡិកាវិភាគសារធាតុរាវ នឹងត្រូវបានពិនិត្យមើលសុក្រឹតភាពរង្វាស់ជារៀងរាល់មួយឆ្នាំម្ដងឬតាមការចាំបាច់ ដោយមន្ត្រីពន្ធដារ ឬអ្នកបច្ចេកទេសទទួលស្គាល់ដោយអគ្គនាយកដ្ឋានពន្ធដារ។

៩-ឧបករណ៍វាស់ចំណុះ ត្រូវបានចាក់សោសុវត្ថិភាព ឬសៀលសុវត្ថិភាព ដោយមន្ត្រីពន្ធដារ។

## ប្រការ៥.- ការគណនាបរិមាណដែលបានផលិត

ទិន្នន័យដែលប្រមូលបានពីឧបករណ៍វាស់ចំណុះ នឹងត្រូវប្រើប្រាស់ និងពិនិត្យដោយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីជាមូលដ្ឋានគណនាបរិមាណស្រាបៀរ ឬភេសជ្ជៈគ្មានជាតិសុរាដែលបានផលិតសរុប។ បរិមាណផលិតសរុបអាចនឹងមានការបាត់បង់នៅពេលច្រក ឬវេចខ្ចប់ក្នុងទម្រង់ផ្សេងៗទៀត ដែលអាចបណ្ដាលមកពីការហៀរចេញ ឬការច្រកមិនបានគ្រប់តាមចំណុះស្ដង់ដារ ឬកត្តាផ្សេងៗ។ បរិមាណបាត់បង់ដែលត្រូវបានអនុញ្ញាត គឺមិនត្រូវលើសពី ១,៥% នៃមូលដ្ឋានដែលបានគណនាបរិមាណស្រាបៀរ ឬភេសជ្ជៈគ្មានជាតិសុរាដែលហូរកាត់ឧបករណ៍វាស់ចំណុះ។

## ប្រការ៦.- ការត្រួតពិនិត្យ

មន្ត្រីពន្ធដារកំពុងប្រចាំការនៅរោងចក្រផលិតស្រាបៀរ និង/ឬភេសជ្ជៈគ្មានជាតិសុរា និងមន្ត្រីពន្ធដារទទួលបន្ទុកមានភារកិច្ចត្រួតពិនិត្យឧបករណ៍វាស់ចំណុះ និងប្រមូលទិន្នន័យបរិមាណផលិតក្នុងគោលបំណងគ្រប់គ្រងប្រមូលចំណូលពន្ធឱ្យមានប្រសិទ្ធភាព។

## ប្រការ៧.- ទោសទណ្ឌ

ដោយមិនទាន់គិតដល់ទោសទណ្ឌដទៃទៀត ការមិនបានដាក់ឧបករណ៍វាស់ចំណុះ ឬការក្លែងបន្លំ ឬកែច្នៃឧបករណ៍វាស់ចំណុះ ដូចមានចែងក្នុងប្រការ៤ នៃប្រកាសនេះ ត្រូវចាត់ទុកជាអំពើរាំងស្ទះលើបទប្បញ្ញត្តិស្ដីពីពន្ធដារ ដូចមានចែងក្នុងមាត្រា១២៨ នៃច្បាប់ស្ដីពីសារពើពន្ធ។

**ប្រការ៨.-  ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក និងអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង ប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអ្នកជាប់ពន្ធដែលមានចែងក្នុងប្រការ២ ត្រូវអនុវត្ត តាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ តទៅ។

ថ្ងៃអង្គារ ១៤រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចប្រការ ៨ “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ